**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានីភ្នំពេញ**

គណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ

លេខ ១១៥ គល

# សេចក្ដីជូនដំណឹង

## ស្ដីពីការអញ្ជើញចូលរួមដេញថ្លៃ

## ការងារស្ថាបនាចាក់បេតុងឆ្អឹងដែក កំរាស់២០ស.ម ផ្លូវលេខ៣៥១ បណ្ដោយ ១,២៧២ម៉ែត្រ ទទឹង៨ម៉ែត្រ ផ្ទៃក្រឡា១០,១៧៦ម៉ែត្រការ៉េ និងស្ថាបនាដាក់លូមូលថ្មីទំហំ១,៥ម៉ែត្រ ក្នុងសាច់ផ្លូវស្ថិតក្នុងសង្កាត់និរោធ និងសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៨

រដ្ឋបាលរាជធានីភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុនក្នុងស្រុក( គិតទាំងសហគ្រាសឯកត្តបុគ្គល) និង ក្រុមហ៊ុនបរទេសទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា រដ្ឋបាលរាជធានីភ្នំពេញ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារស្ថាបនាចាក់បេតុងឆ្អឹងដែក កំរាស់២០ស.ម ផ្លូវលេខ៣៥១ បណ្ដោយ ១,២៧២ម៉ែត្រ ទទឹង៨ម៉ែត្រ ផ្ទៃក្រឡា១០,១៧៦ម៉ែត្រការ៉េ និង ដាក់លូមូលទំហំ១,៥ម៉ែត្រ ក្នុងសាច់ផ្លូវចាប់ពីផ្លូវជាតិលេខ១ ដល់ ផ្លូវចេតស៊ីណាត ស្ថិតក្នុងសង្កាត់និរោធ និងសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ ២០១៨ ។

រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានអាសយដ្ឋានលេខ៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខ ០៨៧ ៧៥៥ ០០៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១០:០០ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១០:០០ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃព្រហស្បតិ៍ ២ រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨

**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងជា**

**ប្រធានគណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ**

**ឃួង ស្រេង**

បានពិនិត្យត្រឹមត្រូវ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ